- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ២២១ សសរ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការចាត់តាំងសមាសភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ចាម
- យោងកម្មវិធីនយោបាយនិងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៧ នៃរដ្ឋសភា
- បានឃើញសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលលេខ០៤ សណន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន
- យោងតាមសំណូមពរចាំបាច់នៃការងារ

សម្រេច

ប្រការ១ .‒

ត្រូវបានកែសម្រួលនិងចាត់តាំង ឯកឧត្តម **ឈួន ម៉ន់** អគ្គនាយក នៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក នៃក្រសួងសាធារណការ និងដឹកជញ្ជូន ពីសមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ចាម មកជាអនុប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ចាម។

ប្រការ២ .‒

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ចាម អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៦កើត ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៤ ខែ មីនា ឆ្នាំ២០២៥

នាយករដ្ឋមន្ត្រី

សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល៖

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៣៣ សហវ.ប្រក.[illegible]

ប្រកាសអន្តរក្រសួង
ស្តីពី
ការតែងតាំងវេជ្ជបណ្ឌិតប្រចាំវិទ្យាស្ថាន និងវេជ្ជបណ្ឌិតជំនួស ប្រចាំនៅអង្គភាពថវិកាវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឆ្នាំង នៃក្រសួងអប់រំ យុវជន និងកីឡា

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្ម មាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្ម មាត្រា៥១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ
- ប្រកាសអន្តរក្រសួងលេខ ៧៧៧ សហវ.ប្រក.អថ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ៦៦៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពថវិកាវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល នៃក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

ប្រការ១ ._

ត្រូវបានតែងតាំងមន្ត្រីរាជការរបស់**អង្គភាពថវិកាវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល ជាអាណាប័កផ្ទេរសិទ្ធិពេញលេញ** នៃក្រសួងអប់រំ យុវជន និងកីឡា ដូចខាងក្រោម៖

១.លោក **សុខ យឺន**	មុខងារជាប្រធានការិយាល័យគណនេយ្យ និងផែនការ ជារដ្ឋទេយ្យករបុរេប្រទាន នៅវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល នៃក្រសួងអប់រំ យុវជន និងកីឡា
២.លោក **ជុំ សុជាត**	មុខងារជាអនុប្រធានការិយាល័យគណនេយ្យ និងផែនការ ជារដ្ឋទេយ្យករបុរេប្រទានរង នៅវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល នៃក្រសួងអប់រំ យុវជន និងកីឡា
៣.លោក **ស័រ វ៉ាន់និត**	មុខងារជាមន្ត្រីការិយាល័យគណនេយ្យ និងផែនការ ជារដ្ឋទេយ្យករបុរេប្រទានរង នៅវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល នៃក្រសួងអប់រំ យុវជន និងកីឡា

ប្រការ២ ._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៣ ._

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល នៃក្រសួងអប់រំ យុវជន និងកីឡា ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៣កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៥

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

កន្លែងទទួល

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ក្រសួងអប់រំ យុវជន និងកីឡា
- ខុទ្ទកាល័យ សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៣៦ សហវ.ប្រក.អសតវ

ប្រកាសអន្តរក្រសួង
ស្តីពី
ការតែងតាំងភ្នាក់ងារបើកផ្តល់ និងភ្នាក់ងារបើកផ្តល់ជំនួស សម្រាប់បើកផ្តល់ប្រាក់បៀវត្ស និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ចនិងវប្បធម៌ ជូនមន្ត្រីរាជការ នៅអង្គភាពថវិកាវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការធ្វើវិសោធនកម្មមាត្រា៥១នៃច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្ដីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ
- បានឃើញប្រកាសអន្តរក្រសួងលេខ ៧៧៧ សហវ.ប្រក.អថ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្ដីពីការអនុវត្តបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអង្គភាពថវិកាវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល

សម្រេច

ប្រការ១._

ប្រាក់បៀវត្សមន្ត្រីរាជការ និង ប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ របស់វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល ត្រូវបើកផ្ដល់តាមរយៈភ្នាក់ងារបើកផ្ដល់ ឬភ្នាក់ងារបើកផ្ដល់ជំនួស។

ប្រការ២._

ត្រូវបានតែងតាំងភ្នាក់ងារបើកផ្ដល់ និងភ្នាក់ងារបើកផ្ដល់ជំនួស របស់វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល ដូចខាងក្រោម ៖

១. លោក **សុខ យឹន**	មុខងារជាប្រធានការិយាល័យគណនេយ្យ និងផែនការ ជាភ្នាក់ងារបើកផ្ដល់ប្រចាំនៅវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល។
២. លោកស្រី **ជិត លឹមហួ**	មុខងារជាមន្ត្រីការិយាល័យគណនេយ្យ និងផែនការ ជាភ្នាក់ងារបើកផ្ដល់ជំនួសប្រចាំនៅវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល។

២/៣

ប្រការ៣._

លោក **សុខ យឺន** ជាភ្នាក់ងារបើកផ្តល់ និងលោកស្រី **ជឹត លីមហួ** ជាភ្នាក់ងារបើកផ្តល់ជំនួស ត្រូវបាន អនុញ្ញាតឱ្យបើកគណនីប្រាក់បញ្ញើនៅអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីទទួលមូលនិធិ សម្រាប់យកទៅ បើកប្រាក់បៀវត្ស និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ជូនមន្ត្រីរាជការ។

ប្រការ៤._

បែបបទនៃការអនុវត្តបើកផ្តល់ប្រាក់បៀវត្ស និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ ត្រូវបានកំណត់ដោយសេចក្តីណែនាំជាក្រោយ។

ប្រការ៥._

ភ្នាក់ងារបើកផ្តល់ត្រូវទទួលខុសត្រូវផ្ទាល់ចំពោះប្រាក់កាស និងមូលនិធិដែលបានទទួលដើម្បីយក ទៅធ្វើការបើកផ្តល់ជូនមន្ត្រីរាជការ។

ប្រការ៦._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៧._

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការ នៃអគ្គាធិការដ្ឋាន និងវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល នៃក្រសួងអប់រំ យុវជន និងកីឡា ប្រធានគ្រប់អង្គភាពក្រោមឱវាទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១០កើត ខែ មាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០២៥

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

កន្លែងទទួល៖

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យ សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ក្រសួងមុខងារសាធារណៈ
-ក្រសួងអប់រំ យុវជន និងកីឡា
-ដូចប្រការ៧
-រាជកិច្ច
-ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០៤៥ សហវ.ប្រក

ប្រកាសអន្តរក្រសួង
ស្តីពី
ការតែងតាំងវិជ្ជមានយុទ្ធភាព

ការតែងតាំងរដ្ឋលេខាធិការចំណូល
នៅក្រសួងព្រះបរមរាជវាំង

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ NS/KRT-34 ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៩៦ ត្រាស់បង្គាប់បង្កើតក្រសួងព្រះបរមរាជវាំង
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា ៩ និងមាត្រា ១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២៣/០២២ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹតលេខ ៧២ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៣៥៤ អនក្រ.បក ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤
- បានឃើញបទបញ្ជាលេខ ០៤ បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរដ្ឋទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ៩២៦ សហវ.ប្រក.អថ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការប្រគល់កាតព្វកិច្ចប្រមូលចំណូលថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងព្រះបរមរាជវាំង

សម្រេច

ប្រការ១._

ត្រូវបានតែងតាំង៖

១- ឯកឧត្តម លី ឈាងគ្រី	ទីប្រឹក្សាក្រសួងព្រះបរមរាជវាំង មានឋានៈស្មើ អនុរដ្ឋលេខាធិការ និងជាអនុប្រធាននាយកដ្ឋានផែនការ-គណនេយ្យ ឱ្យទទួលការងារជា រដ្ឋទេយ្យករចំណូល អមក្រសួងព្រះបរមរាជវាំង
២- ឯកឧត្តម ម៉ុល វ៉ាន់ធី	ជំនួយការក្រសួងព្រះបរមរាជវាំង មានឋានៈស្មើ អគ្គនាយក និងជាអនុប្រធាននាយកដ្ឋានផែនការ-គណនេយ្យ ឱ្យទទួលការងារជា រដ្ឋទេយ្យករចំណូលរង អមក្រសួងព្រះបរមរាជវាំង
៣- ឯកឧត្តម ញឹម ញឿនវីរ៉ូ	ជំនួយការក្រសួងព្រះបរមរាជវាំង មានឋានៈស្មើ អគ្គនាយក និងជាអនុប្រធាននាយកដ្ឋានផែនការ-គណនេយ្យ ឱ្យទទួលការងារជា រដ្ឋទេយ្យករចំណូលរង អមក្រសួងព្រះបរមរាជវាំង

៤- ឯកឧត្តម ជួន ប៊ុនធឿន ជំនួយការក្រសួងព្រះបរមរាជវាំង មានឋានៈស្មើ អគ្គនាយក និងជាអនុប្រធាននាយកដ្ឋានផែនការ-គណនេយ្យ ឲ្យទទួលការងារជា រដ្ឋទេយ្យករចំណូលរង អមក្រសួងព្រះបរមរាជវាំង

៥- លោកស្រី ប៊ុនធឿន សុភ័ក្ត្រនាថ អនុប្រធាននាយកដ្ឋានផែនការ-គណនេយ្យ ឲ្យទទួលការងារជា រដ្ឋទេយ្យករចំណូលរង អមក្រសួងព្រះបរមរាជវាំង ។

ប្រការ២._

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៣._

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ អគ្គាធិការ ប្រធានអង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងព្រះបរមរាជវាំង ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ ... ខែ ... ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០២៥

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

ឧបនាយករដ្ឋមន្ត្រី
និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

សម្ដេចមហាមន្ត្រី គុយ សុផល

កន្លែងទទួល៖
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យ សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០១៥......សហវ.គណ.ក.ប.រ.

សេចក្ដីសម្រេច
ស្ដីពី
ការបង្កើតក្រុមការងារបច្ចេកទេសដោះស្រាយបណ្ដឹងតវ៉ា និង ទំនាក់ទំនងសាធារណៈ ពាក់ព័ន្ធនឹងការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងព្រែកជីកហ្វូណនតេជោ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធាន
អនុគណៈកម្មាធិការ ដើម្បីដោះស្រាយផលប៉ះពាល់សម្រាប់គម្រោងព្រែកជីកហ្វូណនតេជោ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្ដីពីការកែសម្រួលមាត្រា៥០ មាត្រា៥១ មាត្រា៥២ និងមាត្រា៥៣ នៃអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៩៨ សសរ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៤ ស្ដីពីការបង្កើតគណៈកម្មាធិការពិសេស ដើម្បីជំរុញការរៀបចំ និងការអនុវត្តគម្រោងព្រែកជីកហ្វូណនតេជោ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ១០៧ សសរ ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៤ ស្ដីពីការបង្កើតអនុគណៈកម្មាធិការ ដើម្បីដោះស្រាយផលប៉ះពាល់សម្រាប់គម្រោងព្រែកជីកហ្វូណនតេជោ
- បានឃើញសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ១៤១ សសរ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលសមាសភាពអនុគណៈកម្មាធិការ ដើម្បីដោះស្រាយផលប៉ះពាល់សម្រាប់គម្រោងព្រែកជីកហ្វូណនតេជោ
- បានឃើញសេចក្ដីសម្រេចលេខ ១១៣ សហវ.ស.ស.រ.អដផ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៤ ស្ដីពីការបង្កើតក្រុមការងារដោះស្រាយបណ្ដឹងតវ៉ា និងទំនាក់ទំនងសាធារណៈ នៃអនុគណៈកម្មាធិការ ដើម្បីដោះស្រាយផលប៉ះពាល់សម្រាប់គម្រោងព្រែកជីកហ្វូណនតេជោ
- យោងតាមតម្រូវការចាំបាច់របស់អនុគណៈកម្មាធិការ ដើម្បីដោះស្រាយផលប៉ះពាល់សម្រាប់គម្រោងព្រែកជីកហ្វូណនតេជោ

សម្រេច

ប្រការ១.-

ត្រូវបង្កើតក្រុមការងារបច្ចេកទេសដោះស្រាយបណ្ដឹងតវ៉ា និង ទំនាក់ទំនងសាធារណៈ ពាក់ព័ន្ធនឹងការងារដោះស្រាយផលប៉ះពាល់ នៃក្រុមការងារដោះស្រាយបណ្ដឹងតវ៉ា និង ទំនាក់ទំនងសាធារណៈ នៃអនុគណៈកម្មាធិការដើម្បីដោះស្រាយផលប៉ះពាល់សម្រាប់គម្រោងព្រែកជីកហ្វូណនតេជោ ហៅកាត់ **ក.ដ.ទ.ជ.ផ** ដែលមានសមាសភាព ដូចខាងក្រោម៖

១- ឯកឧត្ដម **អ៊ឹម សិទ្ធីរ៉ា**	ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ (អ.ដ.ផ)	ប្រធាន
២- លោក **យ៉េន សុភ័ណ្ណ**	អគ្គនាយករង នៃ អ.ដ.ផ	អនុប្រធានប្រចាំការ
៣- លោក **សេខ វណ្ណឌី**	ប្រធាននាយកដ្ឋានដោះស្រាយផលប៉ះពាល់ទី ១ នៃ អ.ដ.ផ	អនុប្រធាន
៤- លោក **គង់ រដ្ឋា**	ប្រធាននាយកដ្ឋានត្រួតពិនិត្យផ្ទៃក្នុង និងគ្រប់គ្រងទិន្នន័យ នៃ អ.ដ.ផ	អនុប្រធាន
៥- លោក **អ៊ុន ម៉ាល់ឡីវ៉ា**	អនុប្រធាននាយកដ្ឋានត្រួតពិនិត្យផ្ទៃក្នុង និងគ្រប់គ្រងទិន្នន័យ នៃ អ.ដ.ផ	សមាជិក
៦-លោក **ជុំ គីរី**	អនុប្រធាននាយកដ្ឋានត្រួតពិនិត្យផ្ទៃក្នុង និងគ្រប់គ្រងទិន្នន័យ នៃ អ.ដ.ផ	សមាជិក
៧- លោក **ជា សុខហួរ**	អនុប្រធាននាយកដ្ឋានដោះស្រាយផលប៉ះពាល់ទី ១ នៃ អ.ដ.ផ	សមាជិក
៨-លោក **សេខ តារាម៉ុ**	អនុប្រធាននាយកដ្ឋានដោះស្រាយផលប៉ះពាល់ទី ១ នៃ អ.ដ.ផ	សមាជិក
៩- លោក **ឈឹម យុត្តារ័ត្ន**	អនុប្រធាននាយកដ្ឋានដោះស្រាយផលប៉ះពាល់ទី ១ នៃ អ.ដ.ផ	សមាជិក
១០- លោក **ឈាង ឈលីន**	អនុប្រធាននាយកដ្ឋានដោះស្រាយផលប៉ះពាល់ទី ២ នៃ អ.ដ.ផ	សមាជិក

១១- លោក **សុខ សុភក្តិ**	ប្រធានការិយាល័យទទួលពាក្យបណ្តឹង និងទំនាក់ទំនងសាធារណៈ នៃនាយកដ្ឋានត្រួតពិនិត្យផ្ទៃក្នុង និងគ្រប់គ្រងទិន្នន័យ នៃ អ.ជ.ផ	សមាជិក
១២- លោកស្រី **ឌិត ដាវីឡេន**	ប្រធានការិយាល័យគម្រោងសហប្រតិបត្តិការទ្វេភាគីទី ១ នៃនាយកដ្ឋានដោះស្រាយផលប៉ះពាល់ទី ១ នៃ អ.ជ.ផ	សមាជិកា
១៣- កញ្ញា **ឈឹម ឃុតម៉ូនីតា**	អនុប្រធានការិយាល័យគម្រោងវិនិយោគសាធារណៈក្នុងស្រុក និងគម្រោងអភិវឌ្ឍន៍ឯកជនទី១ នៃ អ.ជ.ផ	សមាជិកា
១៤-លោក **ខឹម សុភាមុន្នី**	មន្ត្រី នៃនាយកដ្ឋានកិច្ចការទូទៅ នៃ អ.ជ.ផ	សមាជិក ។

ប្រការ២.-

ក.ដ.ឧ.ដ.ផ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ជាសេនាធិការរបស់ក្រុមការងារដោះស្រាយបណ្តឹងតវ៉ា និង ទំនាក់ទំនងសាធារណៈ នៃអនុគណៈ-កម្មាធិការ ដើម្បីដោះស្រាយផលប៉ះពាល់សម្រាប់គម្រោងព្រែកជីកហ្វូណនតេជោ (ក.ដ.ទ)
- ទទួល និង ពិនិត្យលើបណ្តឹងតវ៉ាពាក់ព័ន្ធនឹងការងារដោះស្រាយផលប៉ះពាល់របស់ប្រជាពលរដ្ឋរងផលប៉ះពាល់ដោយសារគម្រោង
- សហការ និងសម្របសម្រួលជាមួយរដ្ឋបាលខេត្ត, ស្រុក, ឃុំ, មន្ទីរជំនាញពាក់ព័ន្ធ ក្នុងការដោះស្រាយបណ្តឹងតវ៉ានីមួយៗ និង ស្វែងរកដំណោះស្រាយដែលអាចទទួលយកបានសម្រាប់បណ្តឹងតវ៉ា ស្របតាមគោលការណ៍ និង នីតិវិធីជាធរមាន
- ធ្វើការចុះពិនិត្យផ្ទាល់នៅទីវាល ដើម្បីកត់ត្រាព័ត៌មានលម្អិត និងវាយតម្លៃលើបណ្តឹងតវ៉ានីមួយៗ ក្នុងការចាត់ថ្នាក់ទៅតាមប្រភេទ ឬផ្នែកពាក់ព័ន្ធ
- ធ្វើការផ្ទៀងផ្ទាត់ព័ត៌មាននៃបណ្តឹងតវ៉ានីមួយៗ និង ប្រមូលព័ត៌មាន និងទិន្នន័យដែលមានការពាក់ព័ន្ធ
- ជូនដំណឹងដល់អ្នកប្តឹងតវ៉ាអំពីដំណើរការដោះស្រាយ និង លទ្ធផលនៃបណ្តឹងតវ៉ារបស់អ្នកប្តឹង
- រៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យលើបណ្តឹងតវ៉ា និងផ្តល់អនុសាសន៍ចំពោះដំណោះស្រាយជូនប្រធាន ក.ដ.ទ ពិនិត្យ សម្រេច និងផ្តល់ការណែនាំ
- តាមដាន និង វិភាគព័ត៌មាន, សកម្មភាព, ព្រឹត្តិការណ៍ និង សាធារណមតិពាក់ព័ន្ធនឹងការងារដោះស្រាយផលប៉ះពាល់សម្រាប់គម្រោង តាមបណ្តាញផ្សព្វផ្សាយសង្គម និង បណ្តាញសារព័ត៌មានជាតិ និង អន្តរជាតិ
- តាមដាន ចងក្រង និងរៀបចំរបាយការណ៍អំពីព័ត៌មាន ឬមតិយោបល់ដែលបានលើកឡើងពាក់ព័ន្ធការអនុវត្តការងារដោះស្រាយផលប៉ះពាល់នៅលើប្រព័ន្ធផ្សព្វផ្សាយ បណ្តាញសារព័ត៌មាន និង បណ្តាញផ្សព្វផ្សាយសង្គម ជូនប្រធាន ក.ដ.ទ ជ្រាប និងផ្តល់ការណែនាំ
- រៀបចំរបាយការណ៍ស្តីពីការឆ្លើយតបនឹងព័ត៌មាន ឬ មតិយោបល់ដែលបានលើកឡើងពាក់ព័ន្ធនឹងការងារដោះស្រាយផលប៉ះពាល់ ជូនប្រធាន ក.ដ.ទ ពិនិត្យ សម្រេច និងផ្តល់ការណែនាំ
- រៀបចំការផ្សព្វផ្សាយ ឬបណ្តុះបណ្តាលអំពីគោលការណ៍ គោលនយោបាយ បែបបទ និង នីតិវិធីពាក់ព័ន្ធនឹងការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោង ស្របតាមច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន ដល់រដ្ឋបាលខេត្ត, ស្រុក, ឃុំ, មន្ទីរជំនាញ និងបុគ្គលពាក់ព័ន្ធ
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់ប្រធាន ក.ដ.ទ ។

ប្រការ៣.-

វរនុប្រធាន សមាជិក និងសមាជិកានៃ **អ.ជ.ឆ.ជ.ផ** ដូចមានចែងក្នុងប្រការ១ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ ។

អនុប្រធានក្រុមការងារ ដូចមានចែងក្នុងប្រការ១ តាមការប្រគល់សិទ្ធិពីប្រធាន អាចកោះប្រជុំ និងដឹកនាំការងារដើម្បីសម្រេចតាមភារកិច្ចរបស់ក្រុមការងារ ។

ប្រការ៤.-

ប្រធាន **អ.ជ.ឆ.ជ.ផ** អាចស្នើសុំកិច្ចសម្របសម្រួល និងកិច្ចសហការពីរដ្ឋបាលខេត្ត និងមន្ទីរជំនាញពាក់ព័ន្ធ ដែលទីតាំងគម្រោងស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ប្រការ៥.-

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក និង អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] គ.ស.២០២៥

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធាន
អនុគណៈកម្មាធិការ ដើម្បីដោះស្រាយផលប៉ះពាល់សម្រាប់
គម្រោងព្រែកជីកហ្វូណនតេជោ

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

កន្លែងទទួល ៖
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-អនុគណៈកម្មាធិការ ដើម្បីដោះស្រាយផលប៉ះពាល់
សម្រាប់គម្រោងព្រែកជីកហ្វូណនតេជោ
-ដូចប្រការ៥ «ដើម្បីអនុវត្ត»
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..០០៤.....សហវ.អគ.ថ.អអវតាន

សារាចរណែនាំបន្ថែម
ស្តីពី
កាលបរិច្ឆេទបញ្ឈប់ការទទួលអាណត្តិបើកប្រាក់-អាណត្តិនិយតកម្ម និងបញ្ឈប់ប្រតិបត្តិការចំណាយថវិកា ឆ្នាំ២០២៤ ក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) សម្រាប់ថវិកាថ្នាក់ជាតិ និងការរៀបចំរបាយការណ៍បូកសរុបការអនុវត្តចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២៤

យោងសារាចរណែនាំលេខ០១១សហវ.សរ.អថ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការបិទបញ្ជីចំណូល ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២៤ និងដើម្បីជំរុញការទូទាត់កិច្ចប្រតិបត្តិការចំណាយថវិកាឆ្នាំ២០២៤ ក្នុងគោលបំណងធានាដល់ការបិទបញ្ជីចំណាយថវិកាថ្នាក់ជាតិ និងការរៀបចំរបាយការណ៍បូកសរុបការអនុវត្តចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២៤ ប្រព្រឹត្តទៅបានត្រឹមត្រូវ និងទាន់ពេលវេលា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមធ្វើការណែនាំបន្ថែមអំពីនីតិវិធីអនុវត្ត ដូចខាងក្រោម៖

ក. អំពីកាលបរិច្ឆេទបញ្ឈប់ការទទួលអាណត្តិបើកប្រាក់-អាណត្តិនិយតកម្ម និងបញ្ឈប់ប្រតិបត្តិការចំណាយថវិកាឆ្នាំ២០២៤ ក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)

១-ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ ត្រូវប្រមូលសក្ខីបត្រ ឯកសារពាក់ព័ន្ធផ្សេងៗ និងរៀបចំលិខិតយុត្តិការចំណាយថវិកាដែលមានកាលបរិច្ឆេទចុងក្រោយត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ឱ្យបានគ្រប់គ្រាន់និងត្រឹមត្រូវ ដើម្បីបោះផ្សាយអាណត្តិបើកប្រាក់-អាណត្តិនិយតកម្ម និងត្រូវបញ្ចូលព័ត៌មាននិងទិន្នន័យបង្កើតប្រតិបត្តិការចំណាយថវិកា (Voucher) និងអនុម័តក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) រួចបញ្ជូនទៅអ្នកត្រួតពិនិត្យថវិកា យ៉ាងយូរបំផុតត្រឹមវេលាម៉ោង១៧ និង៣០នាទី **ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៥។**

២-អ្នកត្រួតពិនិត្យថវិកា ត្រូវពិនិត្យនិងផ្តល់ទិដ្ឋាការលើអាណត្តិបើកប្រាក់-អាណត្តិនិយតកម្មឆ្នាំ២០២៤ និងប្រតិបត្តិការចំណាយថវិកា (Voucher) ក្នុងប្រព័ន្ធ FMIS រួចបញ្ជូនបន្តទៅរតនាគារថ្នាក់កណ្តាល និងរតនាគាររាជធានី ខេត្ត យ៉ាងយូរបំផុតត្រឹមវេលាម៉ោង១៧ និង៣០នាទី **ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៥។**

៣-ក្រោយកាលបរិច្ឆេទកំណត់វេលាម៉ោង១៧ និង៣០នាទី ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៥ រតនាគារថ្នាក់កណ្តាល និងរតនាគាររាជធានី ខេត្ត ត្រូវបញ្ឈប់ការទទួលអាណត្តិបើកប្រាក់-អាណត្តិនិយតកម្មឆ្នាំ២០២៤

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

ហើយប្រតិបត្តិការចំណាយ (Voucher) ក្នុងប្រព័ន្ធ FMIS ក៏មិនត្រូវបានអនុញ្ញាតឱ្យអនុម័តបញ្ជូនបន្តទៅរតនាគារថ្នាក់កណ្ដាល និងរតនាគាររាជធានី ខេត្ត ទៀតទេ។ អាណត្តិបើកប្រាក់-អាណត្តិនិយតកម្ម និងប្រតិបត្តិការចំណាយ (Voucher) ក្នុងប្រព័ន្ធ FMIS ដែលយឺតយ៉ាវទាំងនោះ ត្រូវចាត់ទុកជាមោឃៈក្នុងកិច្ចប្រតិបត្តិការថវិកាឆ្នាំ២០២៤ ហើយអាណាប័កត្រូវបោះផ្សាយអាណត្តិបើកប្រាក់-អាណត្តិនិយតកម្មថ្មី ព្រមទាំងបង្កើតប្រតិបត្តិការចំណាយថ្មី (Voucher) ក្នុងប្រព័ន្ធ FMIS ដោយប្រើប្រាស់ឥណទានថវិកានៃឆ្នាំ២០២៥។ រតនាគារថ្នាក់កណ្ដាល និងរតនាគាររាជធានី ខេត្ត ត្រូវពិនិត្យនិងទូទាត់អាណត្តិបើកប្រាក់-អាណត្តិនិយតកម្ម និងអនុម័ត Posting ប្រតិបត្តិការចំណាយ (Voucher) ក្នុងប្រព័ន្ធ FMIS **រហូតដល់ត្រឹមវេលាម៉ោង១៧ និង៣០នាទី ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៥**។ ទន្ទឹមនេះ ប្រតិបត្តិការនិយតកម្មនៃរតនាគារឆ្នាំ២០២៤ សម្រាប់ប្រតិបត្តិការចំណូល ចំណាយថវិកា ត្រូវបន្តរហូតដល់**ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៥**។

ខ. អំពីការរៀបចំរបាយការណ៍សរុបអនុវត្តចំណាយថវិកាឆ្នាំ២០២៤

១-ចាប់ពី**ថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៥** អគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវដំណើការបូកសរុបប្រតិបត្តិការរតនាគារទូទាំងប្រទេសអំពីការអនុវត្តចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២៤ យ៉ាងយូរត្រឹម**ថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៥**។

២-ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ ត្រូវបូកសរុបផ្ទៀងផ្ទាត់តួលេខចំណាយថវិកាជាមួយអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល (ចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស) ហើយត្រូវរៀបចំរបាយការណ៍បូកសរុបការអនុវត្តចំណាយថវិកា ដោយរួមបញ្ចូលតួលេខចំណាយថវិការបស់មន្ទីរជំនាញរាជធានី ខេត្ត ដែលស្ថិតនៅក្រោមឱវាទ រួចបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិ-នាយកដ្ឋានចំណាយថវិកា និងអគ្គនាយកដ្ឋានថវិកា-នាយកដ្ឋានថវិកានីយកម្ម) **ឱ្យបានមុនថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៥ ជាកំហិត**។

៣-ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ ត្រូវរៀបចំរបាយការណ៍បូកសរុបការអនុវត្តថវិការបស់ខ្លួនទៅតាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំលេខ០១១សហវ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការបិទបញ្ជីចំណូល ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២៤ រួចបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិ) ឱ្យបានតាមកាលកំណត់ខាងលើ ដើម្បីអាចបូកសរុបនិងរៀបចំសេចក្ដីព្រាងច្បាប់ទូទាត់ថវិកាឆ្នាំ២០២៤ ដាក់ជូនគណៈរដ្ឋមន្ត្រី ពិនិត្យសម្រេច និងស្ថាប័ននីតិប្បញ្ញត្តិពិនិត្យនិងអនុម័ត ឱ្យបានទាន់ពេលវេលា។ ក្នុងករណីក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ ផ្ញើរបាយការណ៍បូកសរុបទូទាត់មិនទាន់ពេលវេលាកំណត់ខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងយកតួលេខរបាយការណ៍របស់អគ្គនាយកដ្ឋានរតនាគារជាតិធ្វើជាតួលេខផ្លូវការ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ អគ្គនាយកដ្ឋានថវិកា អគ្គនាយកដ្ឋានរតនាគារជាតិ និងនាយកដ្ឋានពាក់ព័ន្ធទាំងឡាយ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ ខែ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៥

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

<u>កន្លែងទទួល៖</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋាន គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋានពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរជំនាញរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
លេខ : ០៦២ សសរ

សេចក្តីសម្រេច
ស្តីពី
ការកែសម្រួលសមាសភាពលេខាធិការដ្ឋាន
នៃក្រុមការងារច្បាប់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៨០ អនក្រ.បក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៧៣ អនក្រ.បក ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតអគ្គាធិការដ្ឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ២៨៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរពិសោធន៍ជាតិសំណង់
- យោងសេចក្តីសម្រេចលេខ០៧៧ សសរ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣ ស្តីពីការបង្កើតក្រុមការងារច្បាប់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងតាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សម្រេច

ប្រការ១.-

កែសម្រួលសមាសភាពលេខាធិការដ្ឋាននៃក្រុមការងារច្បាប់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដូចខាងក្រោម៖

១.	លោក **អេ ម៉ុនធឿន**	ប្រធាននាយកដ្ឋាននីតិកម្ម	ប្រធាន
២.	លោក **ម៉ិល តិរ័ត្ន**	អនុប្រធាននាយកដ្ឋាននីតិកម្ម	អនុប្រធាន
៣.	លោកស្រី **ម៉ែន ទូចលាង**	អនុប្រធាននាយកដ្ឋាននីតិកម្ម	អនុប្រធាន
៤.	លោក **ចក់ ឌឿន**	អនុប្រធាននាយកដ្ឋាននីតិកម្ម	សមាជិក
៥.	លោក **ឌិន សុផល**	ប្រធានការិយាល័យនីតិកម្ម	សមាជិក
៦.	លោក **ខ្លូត ច័ន្ទតារា**	អនុប្រធានការិយាល័យនីតិកម្ម	សមាជិក
៧.	លោកស្រី **ហ៊ុន លីកា**	អនុប្រធានការិយាល័យនីតិកម្ម	សមាជិកា
៨.	លោកស្រី **រស់ ចាន់ត្រា**	អនុប្រធានការិយាល័យកិច្ចការគតិយុត្ត	សមាជិកា
៩.	កញ្ញា **ទីម សុវណ្ណារី**	មន្ត្រីនៃនាយកដ្ឋាននីតិកម្ម	សមាជិកា
១០.	លោក **យ៉យ គីមយ៉ាន់**	មន្ត្រីនៃនាយកដ្ឋាននីតិកម្ម	សមាជិក
១១.	កញ្ញា **យ៉េង មួយណេង**	មន្ត្រីជាប់កិច្ចសន្យានៃនាយកដ្ឋាននីតិកម្ម	សមាជិកា
១២.	កញ្ញា **ឈាង ដារី**	មន្ត្រីជាប់កិច្ចសន្យានៃនាយកដ្ឋាននីតិកម្ម	សមាជិកា
១៣.	លោក **កែម បញ្ញា**	មន្ត្រីជាប់កិច្ចសន្យានៃនាយកដ្ឋានបុគ្គលិក	សមាជិក
១៤.	កញ្ញា **នាង កន្និដ្ឋា**	ជំនួយការរដ្ឋលេខាធិការ	សមាជិកា
១៥.	កញ្ញា **សេង ទិមាន**	អ្នកស្ម័គ្រចិត្តនៃនាយកដ្ឋាននីតិកម្ម	សមាជិកា
១៦.	កញ្ញា **ហុង បណ្ណែត**	ជំនួយការមេធាវីស្ម័គ្រចិត្ត	សមាជិកា
១៧.	កញ្ញា **ហោ សុផាវត្តី**	ជំនួយការមេធាវីស្ម័គ្រចិត្ត	សមាជិកា
១៨.	លោក **សុខ សុវណ្ណ**	ជំនួយការមេធាវីស្ម័គ្រចិត្ត	សមាជិក
១៩.	លោក **ឌីង ហុងលាង**	ជំនួយការមេធាវីស្ម័គ្រចិត្ត	សមាជិក
២០.	កញ្ញា **អ៊ែល មុន្នីម៉ារីឡែន**	ជំនួយការមេធាវីស្ម័គ្រចិត្ត	សមាជិកា
២១.	លោក **ហួម ឆាយ៉ា**	ជំនួយការមេធាវីស្ម័គ្រចិត្ត	សមាជិក
២២.	កញ្ញា **ទុន គីមរ៉ុង**	ជំនួយការមេធាវីស្ម័គ្រចិត្ត	សមាជិកា

លេខាធិការដ្ឋាននៃក្រុមការងារច្បាប់ មានភារកិច្ចដូចខាងក្រោម៖

- ជួយក្រុមការងារច្បាប់ក្នុងការសិក្សាស្រាវជ្រាវ និងចងក្រងបទប្បញ្ញត្តិច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីធ្វើការអភិវឌ្ឍនិងផ្សព្វផ្សាយ

- ពិនិត្យនិងធ្វើការកែសម្រួលបឋមលើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត មុនដាក់ជូនកិច្ចប្រជុំរបស់ក្រុមការងារច្បាប់ និងគណៈកម្មការចំណុះ
- រៀបចំកម្មវិធីប្រជុំ និងធ្វើកំណត់ត្រានៃកិច្ចប្រជុំរបស់ក្រុមការងារច្បាប់ និងគណៈកម្មការចំណុះ
- កែសម្រួលសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតតាមស្មារតីអង្គប្រជុំរបស់ក្រុមការងារច្បាប់ និងគណៈកម្មការចំណុះ
- ធ្វើកំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមការងារច្បាប់ និងគណៈកម្មការចំណុះ
- ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំអំពីលទ្ធផលនៃកិច្ចប្រជុំរបស់ក្រុមការងារច្បាប់ និងគណៈកម្មការចំណុះ
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ក្រុមការងារច្បាប់
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់ប្រធានក្រុមការងារច្បាប់។

ប្រការ២._

រាល់សេចក្តីសម្រេចនិងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

ប្រការ៣._

អគ្គលេខាធិការ គ្រប់អគ្គនាយក អគ្គាធិការ គ្រប់ប្រធាននាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដូចមានរាយនាមក្នុងប្រការ ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច័ន្ទ ១១រោច ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ២០២៥

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សាយ សំអាល់

កន្លែងទទួល៖

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

លេខ ០១៤ ស.ស.រ-កពារ.

សេចក្តីសម្រេច

ស្តីពី

ការបង្កើតក្រុមការងារចំពោះកិច្ចទទួលបន្ទុកសហការជាមួយក្រសួង/ស្ថាប័នជំនាញពាក់ព័ន្ធ ក្នុងការសម្របសម្រួលរៀបចំផែនការថវិកាចំណាយ និងសកម្មភាពការងារប្រចាំឆ្នាំ របស់ការិយាល័យអនុព័ន្ធយោធាកម្ពុជាប្រចាំនៅក្រៅប្រទេស

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ៣១ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធនិងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- យោងតាមសំណូមពរចាំបាច់នៃការងារ

សម្រេច

ប្រការ១ ._

ត្រូវបានបង្កើតក្រុមការងារចំពោះកិច្ចទទួលបន្ទុកសហការជាមួយក្រសួង/ស្ថាប័នជំនាញពាក់ព័ន្ធក្នុងការសម្របសម្រួលរៀបចំផែនការថវិកាចំណាយ និងសកម្មភាពការងារប្រចាំឆ្នាំរបស់ការិយាល័យអនុព័ន្ធយោធាកម្ពុជាប្រចាំនៅក្រៅប្រទេស ដែលមានសមាសភាពដូចខាងក្រោម៖

១-ឧត្តមសេនីយ៍ទោ ឌួង ឧត្តម អគ្គនាយករង អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច ប្រធាន

២-ឧត្តមសេនីយ៍ត្រី យុត សុផាណ្ណារិទ្ធិ នាយក នាយកដ្ឋានប្រតិបត្តិការក្រៅប្រទេស អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច អនុប្រធានប្រចាំការ

៣-ឧត្តមសេនីយ៍ត្រី ទៀង ពៅ នាយក នាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច អនុប្រធាន

៤-ឧត្តមសេនីយ៍ត្រី ផន យិនយូរ៉ា នាយករង នាយកដ្ឋានទាក់ទងអន្តរជាតិ អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស អនុប្រធាន

៥-ឧត្តមសេនីយ៍ត្រី កុសល សុវណ្ណមរកត នាយករង នាយកដ្ឋានហិរញ្ញវត្ថុ អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ អនុប្រធាន

៦-ឧត្តមសេនីយ៍ត្រី ឈុន វណ្ណា នាយករង នាយកដ្ឋានប្រតិបត្តិការក្រៅប្រទេស អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច សមាជិក

៧-ឧត្តមសេនីយ៍ត្រី ប៉ែន ចាន់សយ នាយករង នាយកដ្ឋានទាក់ទងអន្តរជាតិ អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស សមាជិក

៨-វរសេនីយ៍ឯក ឈន បូរី នាយការិយាល័យសហប្រតិបត្តិការ នាយកដ្ឋានទាក់ទងអន្តរជាតិ អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស សមាជិក

៩-វរសេនីយ៍ទោ ឡេង យុទ្ធី នាយការិយាល័យទំនាក់ទំនងអន្តរជាតិ អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច សមាជិក

១០-វរសេនីយ៍ទោ គិន រិទ្ធី នាយរងការិយាល័យបុគ្គលិក អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច សមាជិក

១១-វរសេនីយ៍ទោ ឡុង កែវដាលីយ៉ា នាយរងការិយាល័យទំនាក់ទំនងអន្តរជាតិ នាយកដ្ឋានប្រតិបត្តិការក្រៅប្រទេស អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច សមាជិក

១២-វរសេនីយ៍ទោ ឡុង លីម ជំនួយការ នាយកដ្ឋានប្រតិបត្តិការក្រៅប្រទេស អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច សមាជិក

១៣-វរសេនីយ៍ទោ ឡុង សុផល ជំនួយការ នាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច សមាជិក

១៤-វរសេនីយ៍ត្រី អ៊ាង ផល្លា នាយរងការិយាល័យទំនាក់ទំនងអន្តរជាតិ នាយកដ្ឋានប្រតិបត្តិការក្រៅប្រទេស អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច សមាជិក

១៥-វរសេនីយ៍ត្រី តឹក ស៊ាងលីម នាយរង ការិយាល័យភស្តុភារហិរញ្ញវត្ថុ អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច សមាជិក

១៦-វរសេនីយ៍ត្រី លន់ សុខគាង នាយរងការិយាល័យប្រមូលព័ត៌មាន នាយកដ្ឋានប្រតិបត្តិការក្រៅប្រទេស អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច សមាជិក

១៧-វរសេនីយ៍ត្រី ឡេង ភិចឈៀ ជំនួយការ អគ្គនាយក អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច សមាជិក

១៨-វរសេនីយ៍ត្រី វ៉ែន រដ្ឋាវង្ស ជំនួយការ អគ្គនាយក អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច សមាជិក

១៩-អនុសេនីយ៍ឯក ជា ពៅរិត្យា នាយផ្នែករដ្ឋបាល នាយកដ្ឋានប្រតិបត្តិការក្រៅប្រទេស អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច សមាជិក

២០-អនុសេនីយ៍ទោ ពុំ សុវណ្ណ ជំនួយការ ការិយាល័យរដ្ឋបាល អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច សមាជិក។

ប្រការ២ .-

ក្រុមការងារនេះមានភារកិច្ចដូចខាងក្រោម៖

-ដឹកនាំជំរុញ ដំណើរការរៀបចំនិងពិនិត្យលើផែនការថវិកា ការស្នើសុំអាចប្រព្រឹត្តទៅដោយភាពរលូន មានគណនេយ្យភាព តម្លាភាព ស្របតាមទិសដៅនិងសកម្មភាពការងារ

-ដឹកនាំរៀបចំនិងសម្របសម្រួលជាមួយការិយាល័យអនុព័ន្ធយោធារៀបចំផែនការថវិកាឱ្យគ្រប់ជ្រុងជ្រោយ និងប្រសិទ្ធភាពខ្ពស់ឆ្លើយតបការងារប្រចាំថ្ងៃ

-សហការសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីធានាដល់ការស្នើសុំថវិកាទទួលបានការអនុម័ត ឆ្លើយតបនឹងតម្រូវការឱ្យទាន់ពេលវេលា

-ធ្វើរបាយការណ៍វឌ្ឍនភាពការងារជូនថ្នាក់ដឹកនាំជ្រាប ស្នើសុំមតិណែនាំនិង/ឬស្នើសុំការសម្រេចដ៏ខ្ពង់ខ្ពស់

-អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីរដ្ឋមន្ត្រី/ថ្នាក់ដឹកនាំ។

ប្រការ៣ .-

ក្រុមការងារនេះមានក្រុមការងារជំនាញតាមក្រុមដើម្បីជួយសម្របសម្រួលនិងអនុវត្តការងារដូចខាងក្រោម៖

ក.ក្រុមការងារត្រួតពិនិត្យវាយតម្លៃ និងបូកសរុបកញ្ចប់ថវិកាការិយាល័យអនុព័ន្ធយោធាប្រចាំនៅក្រៅប្រទេស

១-ឧត្តមសេនីយ៍ត្រី យុត សុផាណ្ណារិទ្ធិ នាយក នាយកដ្ឋានប្រតិបត្តិការក្រៅប្រទេស អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច ប្រធាន

២-ឧត្តមសេនីយ៍ត្រី ផន យិនយូរ៉ា នាយករង នាយកដ្ឋានទាក់ទងអន្តរជាតិ អគ្គនាយកដ្ឋាននយោបាយនិងកិច្ចការបរទេស អនុប្រធាន

៣-ឧត្តមសេនីយ៍ត្រី កុសល សុវណ្ណមរកត នាយករង នាយកដ្ឋានហិរញ្ញវត្ថុ អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ អនុប្រធាន

៤-ឧត្តមសេនីយ៍ត្រី ឈុន វណ្ណា នាយករង នាយកដ្ឋានប្រតិបត្តិការក្រៅប្រទេស អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច សមាជិក

៥-វរសេនីយ៍ទោ ឡេង យុទ្ធី នាយការិយាល័យទំនាក់ទំនងអន្តរជាតិ នាយកដ្ឋានប្រតិបត្តិការក្រៅប្រទេស អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច សមាជិក

៦-វរសេនីយ៍ទោ ឡុង កែវដាលីយ៉ា នាយរងការិយាល័យទំនាក់ទំនងអន្តរជាតិ នាយកដ្ឋានប្រតិបត្តិការក្រៅប្រទេស អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច សមាជិក

៧-វរសេនីយ៍ទោ ឡុង លីម ជំនួយការ នាយកដ្ឋានប្រតិបត្តិការក្រៅប្រទេស អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច សមាជិក

៨-វរសេនីយ៍ត្រី អ៊ាង ផល្លា នាយរងការិយាល័យទំនាក់ទំនងអន្តរជាតិ នាយកដ្ឋានប្រតិបត្តិការក្រៅប្រទេស អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច សមាជិក

៩-វរសេនីយ៍ត្រី តឹក ស៊ាងលីម នាយរង ការិយាល័យភស្តុភារហិរញ្ញវត្ថុ អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច សមាជិក

១០-វរសេនីយ៍ត្រី ឡេង ភិចឈៀ ជំនួយការ អគ្គនាយក អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច សមាជិក

១១-វរសេនីយ៍ត្រី វ៉ែន រដ្ឋាវង្ស ជំនួយការ អគ្គនាយក អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច សមាជិក

១២-អនុសេនីយ៍ឯក ជា ពៅរិត្យា នាយផ្នែករដ្ឋបាល នាយកដ្ឋានប្រតិបត្តិការក្រៅប្រទេស អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច សមាជិក។

ក្រុមការងារនេះ មានភារកិច្ចៈ

-ប្រមូលគម្រោងចំណាយប្រចាំឆ្នាំដើម្បីពិនិត្យវាយតម្លៃផែនការចំណាយលម្អិតឱ្យស្របតាមផែនការការងារ

-ធ្វើការណែនាំ សម្របសម្រួល និងជូនដំណឹងការងារដែលពាក់ព័ន្ធ

-ត្រួតពិនិត្យការចំណាយស្របតាមផែនការការងារ

-ស្នើសុំគោលការណ៍បញ្ជូនសំណើថវិកាទៅក្រសួង/ស្ថាប័នពាក់ព័ន្ធ

-អនុវត្តភារកិច្ចផ្សេងៗតាមការប្រគល់ពីប្រធានក្រុមការងារចំពោះកិច្ច។

ខ.ក្រុមការងារសម្របសម្រួលជាមួយក្រសួង/ស្ថាប័នពាក់ព័ន្ធ

១-ឧត្តមសេនីយ៍ត្រី ផន យិនយូរ៉ា	នាយករង នាយកដ្ឋានទាក់ទងអន្តរជាតិ អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស	ប្រធាន
២-ឧត្តមសេនីយ៍ត្រី ឈុន វណ្ណា	នាយករង នាយកដ្ឋានប្រតិបត្តិការក្រៅប្រទេស អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច	អនុប្រធាន
៣-ឧត្តមសេនីយ៍ត្រី កុសល សុវណ្ណមរកត	នាយករង នាយកដ្ឋានហិរញ្ញវត្ថុ អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ	អនុប្រធាន
៤-ឧត្តមសេនីយ៍ត្រី ប៉ែន ចាន់សយ	នាយករង នាយកដ្ឋានទាក់ទងអន្តរជាតិ អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស	សមាជិក
៥-វរសេនីយ៍ឯក ឈន បូរី	នាយការិយាល័យសហប្រតិបត្តិការ នាយកដ្ឋានទាក់ទងអន្តរជាតិ អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស	សមាជិក
៦-វរសេនីយ៍ទោ គិន រិទ្ធី	នាយរងការិយាល័យបុគ្គលិក អគ្គនាយកដ្ឋាន ស្រាវជ្រាវ-ចារកិច្ច	សមាជិក
៧-វរសេនីយ៍ទោ ឡុង កែវដាលីយ៉ា	នាយរងការិយាល័យទំនាក់ទំនងអន្តរជាតិ នាយកដ្ឋានប្រតិបត្តិការ ក្រៅប្រទេស អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច	សមាជិក
៨-វរសេនីយ៍ត្រី តឹក ស៊ាងលីម	នាយរងការិយាល័យភស្តុភារហិរញ្ញវត្ថុ អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច	សមាជិក
៩-វរសេនីយ៍ត្រី វ៉ែន រដ្ឋាវង្ស	ជំនួយការ អគ្គនាយក អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច	សមាជិក។

ក្រុមការងារនេះមានភារកិច្ចៈ

-ធ្វើការទំនាក់ទំនង សហការ សម្របសម្រួលជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធឱ្យទាន់ពេលវេលា

-តាមដានវឌ្ឍនភាពការងារ និងធ្វើការផ្សព្វផ្សាយព័ត៌មានដល់បណ្ដាអនុព័ន្ធយោធាឱ្យបានជ្រាប

-ពិនិត្យ ផ្ទៀងផ្ទាត់ និងផ្ដល់យោបល់លើផែនការចំណាយអាទិភាពប្រចាំឆ្នាំ

-ក្រុមការងារបង្គោលពិភាក្សាលើគម្រោងថវិកាជាមួយក្រសួងការបរទេសនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-អនុវត្តភារកិច្ចផ្សេងៗតាមការប្រគល់ពីប្រធានក្រុមការងារចំពោះកិច្ច។

គ.ក្រុមការងាររដ្ឋបាលទូទៅ

១-ឧត្តមសេនីយ៍ត្រី ទៀង ពៅ	នាយក នាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច	ប្រធាន
២-ឧត្តមសេនីយ៍ត្រី ឈុន វណ្ណា	នាយករង នាយកដ្ឋានប្រតិបត្តិការក្រៅប្រទេស អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច	អនុប្រធាន
